# បច្ចេកទេសបំប៉នកូនត្រី

## ១_ការថែបំប៉នកូនត្រីក្នុងស្រះ

ការថែបំប៉នកូនត្រីក្នុងស្រះ  ត្រូវបំប៉នជាពីរដំណាក់កាលផ្សេងៗគ្នាគឺ  :  ដំណាក់កាលថែបំប៉នកូនត្រីម្សៅ  និងដំណាក់កាលថែបំប៉នកូនត្រីពូជ។  សម្រាប់កសិករមានដើមទុនតិច  គួរជ្រើសរើសប្រភេទត្រីទាំងឡាយណាដែលស៊ីចំណីធម្មជាតិមានស្រាប់នៅក្នុងស្រះជាអាហារសំខាន់  និងចំណីបន្ថែមអាចរកបាន  ឬមានស្រាប់នៅតាមមូលដ្ឋាន ភូមិ ឃុំ របស់ខ្លួន ដូចជា កន្ទក់  ចុងអង្ករ ជន្លេន កណ្ដៀរ  ចកបាយទា កាកសំណល់បន្លែ  ឬ ផ្ទះបាយជាដើម...។ល។  ប្រភេទត្រីទាំងនោះរួមមានដូចជា : ត្រីឆ្ពិន  ត្រីកន្ធរ ត្រីទីឡាព្យ៉ា ត្រីកាបសាមញ្ញ ត្រីកាបស និងត្រីកាបឥណ្ឌា (ដូចរូបភាពខាងក្រោម)  ។


ត្រីឆ្ពិន


ត្រីកន្ធរ


ត្រីទីឡាព្យ៉ា


ត្រីកាបសាមញ្ញ


ត្រីកាបស


ត្រីកាបឥណ្ឌា (ម្រីហ្គាល់)


ត្រីកាបឥណ្ឌា (រ៉ូហ៊ូ)

## ក. ការថែបំប៉នកូនត្រីម្សៅ និងកូនត្រីពូជ

កូនត្រីម្សៅ គឺជាកូនត្រីមានទំហំតូចៗ ដែលទើបនឹងញាស់ និងចាប់ផ្ដើមចេះស៊ីចំណី។ ចំណែកកូនត្រីពូជ មានទំហំធំជាងកូនត្រីម្សៅ។ ការថែបំប៉នកូនត្រីម្សៅក្នុងស្រះទាមទារត្រូវយកចិត្តទុកដាក់បំផុត ដើម្បីឱ្យកូនត្រីមានបរិមាណរស់ច្រើន និងធំធាត់ឆាប់រហ័ស។ ក្រោយពីថែបំប៉នកូនត្រីម្សៅក្នុងរយៈពេលពី ២- ៣ សប្ដាហ៍ នោះកូនត្រីមាន ទំហំកាន់តែធំ ធ្វើឱ្យទីធ្លារស់នៅកាន់តែចង្អៀត ដែលមានផលប៉ះពាល់មិនល្អដល់ការលូតលាស់របស់កូនត្រី ដូច្នេះចាំបាច់យើងត្រូវចាប់រំលែកកូនត្រីមកដាក់បំប៉នក្នុងស្រះមួយផ្សេងទៀត ដើម្បីឱ្យកូនត្រីលូតលាស់បានឆាប់រហ័ស។ បច្ចេកទេសថែបំប៉នកូនត្រីម្សៅ និងកូនត្រីពូជ មានដូចខាងក្រោមនេះ :

### ក១- ស្រះ និងការរៀបចំស្រះបំប៉នកូនត្រីម្សៅ

- ស្រះថែបំប៉នកូនត្រីម្សៅ គួរមានទំហំតូចល្មម ដើម្បីងាយស្រួលក្នុងការថែបំប៉ន ដូចជាទំហំពី ៥០ ទៅ ១៥០ ម៉ែត្រការេ ឬមានបណ្ដោយពី ១០ ម៉ែត្រ ទៅ ២០ ម៉ែត្រ ទទឹងមានពី ៥ ទៅ ១០ ម៉ែត្រ និងមានជម្រៅ ០.៥ ម៉ែត្រ (ដូចរូបភាពខាងក្រោម) ។
- ដើម្បីថែបំប៉នកូនត្រីម្សៅមានបរិមាណរស់ច្រើន ស្រះថែបំប៉នកូនត្រីម្សៅ ចាំបាច់ត្រូវរៀបចំឱ្យបានស្អាតល្អ គឺគ្មានត្រីកាច កង្កែប កូនក្អាត់ ពស់ អន្ទង់ សត្វដង្កូវរែកទោម ក្ដាមទូក.... ។ល។ ដែលស៊ីបំផ្លាញកូនត្រីម្សៅជាអាហារ។



ស្រះថែបំប៉នកូនត្រីមានសំណាញ់ព័ទ្ធជុំវិញ



រូបភាពសត្វល្អិត បំផ្លាញកូនត្រី

- ដូចនេះ ស្រះត្រូវបូមទឹកពង្រីងឱ្យអស់ ដើម្បីចាប់ត្រីកាច កង្កែប កូនក្អាត់ ពស់ អន្ទង់....។ល។ ទាំងអស់នេះ កុំឱ្យមានសល់ក្នុងស្រះ រួចស្ការភក់បាតស្រះទុកឱ្យមានជម្រៅ តែពី ១០ ទៅ ២០ សង់ទីម៉ែត្រ ។
- រួចបាចកំបោរពី ៣ ទៅ ៥ គ.ក្រ ក្នុង ១០០ ម$^{២}$ សម្រាប់ស្រះចាស់ ឬ ពី ១០ ទៅ ១៥ គ.ក្រ ក្នុង ១០០ម$^{២}$ សម្រាប់ស្រះថ្មី និងទុកស្រះហាលថ្ងៃ ចំនួន ២-៣ ថ្ងៃ ។
- បន្ទាប់មកបង្ហូរទឹកចូលស្រះដោយប្រើតម្រងច្រោះ ដើម្បីការពារកុំឱ្យមានត្រីកាច ឬសត្វល្អិតចូលស្រះ និងត្រូវមានទ្រនាប់ទ្រទឹកបាញ់ចូលក្នុងស្រះ ដើម្បីកុំឱ្យទឹកស្រះល្អក់ ។



ស្រះបាចកំបោរហើយ




ស្រះបញ្ចូលទឹកដោយប្រើតម្រង និងទ្រនាប់

- ក្រោយពីស្រះបង្ហូរទឹកចូល និងសាបជាតិកំបោរអស់ហើយ ត្រូវលែងកូនត្រីម្យៅចូលក្នុងស្រះភ្លាម ដើម្បីកុំឱ្យមានសត្វល្អិតកើតក្នុងស្រះ មុនពេលដាក់កូនត្រីម្យៅបំប៉ន ។
- ដូចនេះ ពេលរៀបចំស្រះថែបំប៉នកូនត្រីម្យៅ មិនត្រូវប្រើជីដាក់ក្នុងស្រះទេ ព្រោះវានឹងកើតសត្វល្អិតច្រើន ស៊ីបំផ្លាញកូនត្រីម្យៅ។ ប៉ុន្តែ ក្រោយពេលបំប៉នកូនត្រីម្យៅមានទំហំធំ ស្រះចាំបាច់ត្រូវប្រើជី ដើម្បីបង្កើនបរិមាណចំណីធម្មជាតិ ដែលជាចំណីសំខាន់សម្រាប់កូនត្រី (មានបញ្ជាក់ពីរបៀបប្រើជី ក្រោយពេលដាក់កូនត្រីចិញ្ចឹមបំប៉ននៅមេរៀនខាងក្រោយ) ។

## ក២ - ស្រះ និងការរៀបចំស្រះបំប៉នកូនត្រីពូជ

- ស្រះថែបំប៉នកូនត្រីពូជ អាចមានទំហំប៉ុនទំហំស្រះថែបំប៉នកូនត្រីម្សៅ ឬមានទំហំធំជាងនេះក៏បាន ប៉ុន្តែកុំឱ្យមានទំហំធំពេក ព្រោះពិបាកគ្រប់គ្រង។ ជាទូទៅសម្រាប់កសិករ ទំហំស្រះបំប៉នកូនត្រីពូជអាចមានពី ១៥០ ទៅ ២០០ ម៉ែត្រការេ ឬមានបណ្ដោយពី ១៥ ម៉ែត្រ ទៅ ២០ ម៉ែត្រ និងទទឹង ១០ ម៉ែត្រ និងមានជម្រៅពី ០.៥ ម៉ែត្រ ទៅ ១ ម៉ែត្រ។
- ក្រោយពីកូនត្រីម្សៅមានទំហំធំ ត្រូវចាប់វាផ្ទេរទៅបំប៉នក្នុងស្រះមួយផ្សេងទៀត ដែលត្រូវរៀបចំតាមវិធីដូចបានរៀបរាប់ខាងលើ តែស្រះនេះត្រូវប្រើជី ដើម្បីបង្កើនសត្វល្អិតប្លង់តុង ដែលជាចំណីសំខាន់របស់កូនត្រីពូជ។
- ដូចនេះ ស្រះថែបំប៉នកូនត្រីពូជ ត្រូវប្រើជីដាក់ក្នុងស្រះ។ ប្រភេទជីដែលប្រើសម្រាប់កសិករ គឺ ជីធម្មជាតិ ដូចជា លាមកគោ ក្របី លាមកមាន់ ទា ជ្រូក ជាដើម ដោយដាក់វាត្រាំក្នុងរណ្ដៅជីរយៈពេល ១ សប្ដាហ៍ ទើបបង្ហូរទឹកជីនោះចូលទៅក្នុងស្រះ (ដូចរូបភាពខាងក្រោម)។
- គួរកុំប្រើជីគីមី ដែលនាំឱ្យខាតបង់ថវិកា ព្រោះប្រើតែជីធម្មជាតិក៏ធ្វើឱ្យទឹកស្រះមានពណ៌បៃតង និងសម្បូរចំណីធម្មជាតិបានដែរ
- ក្រោយពេលដាក់ជីហើយ រយៈពេលប្រមាណពី ២ ទៅ ៣ថ្ងៃ បើសង្កេតឃើញទឹកស្រះមានពណ៌បៃតង ទើបលែងកូនត្រីពូជចូលក្នុងស្រះបាន។
- ម្យ៉ាងទៀត ដើម្បីថែបំប៉នកូនត្រីម្សៅ និងកូនត្រីពូជមានបរិមាណរស់ច្រើន គួរព័ទ្ធសំណាញ់ជុំវិញស្រះ ដើម្បីការពារកុំឱ្យត្រីកាច ឬកង្កែប កូនក្អាត់ ពស់ ឬកណ្ដុរចូលក្នុងស្រះស៊ីកូនត្រី (ដូចរូបភាពខាងក្រោម)។




ការរៀបចំស្រះដោយប្រើរណ្ដៅជី

ស្រះបំប៉នកូនត្រីរៀបចំហើយ
និងមានសំណាញ់ព័ទ្ធជុំវិញ




ក ៣ -